ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

# សាលក្រមព្រហ្មទណ្ឌ

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ÷ ១៤១៥ អ.ក
ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១
សាលក្រមលេខ÷ ៣១ (ឌ)
ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល
នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងពីរ និងសាមសិបនាទីរសៀល និងប្រកាសសាលក្រម
នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដែលមានសមាសភាពដូចតទៅ÷

### ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្តាល

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្តាល

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ១៤១៥ អ.ក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ មានជនជាប់ចោទ

១. ឈ្មោះ [redacted] HUAHONG (ហ៉ាំង ហ្វាហុង) ភេទប្រុស កើតឆ្នាំ១៩៧១ (អាយុ៥០ឆ្នាំ) ជនជាតិចិន មុខរបរ អ្នកចាំដី កម្រិតវប្បធម៌ ថ្នាក់ទី២ ទីកន្លែងកំណើតនៅប្រទេសចិន ទីលំនៅបច្ចុប្បន្នភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ឈិនឡុង (រស់) ម្តាយឈ្មោះ [redacted] លីឈិញ(ស្លាប់) ប្រពន្ធឈ្មោះ [redacted] លីវ(រស់) មានកូនចំនួន០៥នាក់ ជានីតិជន ទោសពីមុនគ្មាន។(ក្រៅឃុំ)

ត្រូវជាប់ចោទពីបទ÷ ធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

-មានលោក [redacted] ជាអ្នកបកប្រែភាសាចិន ។



Scanned with CamScanner

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ដើមបណ្តឹងរដ្ឋប្បវេណី÷

ឈ្មោះ [redacted] វុទ្ធី ហៅធី ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ មេការលក់ដីឡូតិ៍ កម្រិតវប្បធម៌ថ្នាក់ទី៩ ទីកន្លែងកំណើតនៅភូមិក្នុងភាំង ឃុំភាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្នភូមិក្នុងភាំង ឃុំភាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ជានីតិជន។

-បានឃើញ ដីកាដំណោះស្រាយលេខ÷១៦៤០ ដកដស/២១ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាចាត់តាំងចៅជំនុំជម្រះលេខ÷១៧៧២ ដកចស/២១ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

**អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ ÷**

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង០៧ និង០០នាទីព្រឹក ស្ថិតនៅក្នុងភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល មានជនជាប់ចោទឈ្មោះ [redacted] ហួហុង បានធ្វើសកម្មភាពជីកគាស់ផ្លាកយីហោគម្រោងដីឡូតិ៍ឈ្មោះ MS ខណៈពេលនោះមានឈ្មោះ [redacted] វុទ្ធី ដែលជាមេការលក់ដីឡូតិ៍ បានចូលទៅហាមឃាត់ជនជាប់ចោទ ប៉ុន្តែជនជាប់ចោទមិនព្រមស្តាប់ឡើយ។ លុះដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង០៧ និង០០ នាទីព្រឹក ឈ្មោះ [redacted] វុទ្ធី ដែលជាមេការលក់ដីឡូតិ៍ MS បានបើករថយន្តទៅមើលក៏ឃើញផ្លាកយីហោដួលរលំដល់ដីបណ្តាលឱ្យខូចខាត។ ក្រោយមកទើបឈ្មោះ [redacted] វុទ្ធី មកដាក់ពាក្យបណ្តឹងនៅអធិការដ្ឋាននគរបាលស្រុកពញាឮឈានដល់ការឃាត់ខ្លួនជនជាប់ចោទខាងលើតែម្តង។

**នារពលសចនាការ ÷**

១. ជនជាប់ចោទឈ្មោះ [redacted] HUAHONG (ហាំង ហួហុង) បានឆ្លើយថា÷ កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង០៧ និង០០នាទីព្រឹក ខ្លួនបានជីកដីបណ្តាលឱ្យប៉ះពាល់ផ្លាក់យីហោគម្រោងដីឡូតិ៍ MS ស្ថិតនៅភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ដោយសារតែផ្លាកយីហោគម្រោងដីឡូតិ៍ MS នេះធំ បណ្តាលឱ្យប៉ះពាល់កន្លែងស្នាក់នៅរបស់ខ្លួន ហើយកន្លងមក ខ្លួនក៏ធ្លាប់បានប្រាប់ម្ចាស់ផ្លាកយីហោឱ្យលើកចេញដែរ តែមិនយកចេញឡើយ។ ខ្លួនមិនដឹងថាផ្លាកយីហោនោះដួលរលំឬអត់ទេ។

២. ក្រឡាបញ្ជីអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វុទ្ធី កាលពីនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា÷ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង០៧ព្រឹក ឈ្មោះ [redacted] ភេទប្រុស ជាចៅកែដីឡូតិ៍ បានប្រើឱ្យខ្លួនដើរត្រួតពិនិត្យស្លាកយីហោដាក់លក់ដីឡូតិ៍ ពីព្រោះមានគេរាយការណ៍ថា មានគេគាស់បង្គោលផ្លាកយីហោ នៅមុំផ្លូវជាតិលេខ៥១ ស្ថិតនៅភូមិផ្សារដែកលើ។ បន្ទាប់ពី

ឈ្មោះ [redacted] ប្រាប់ដូច្នេះ ខ្លួនក៏បានជិះរថយន្តឃ្លាំមើល ស្រាប់តែឃើញមានស្នាមកាយអាចម៍ដីចេញពីបង្គោលដាំស្លាកយីហោ ស្ថិតនៅភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ។ ឃើញដូច្នេះ ខ្លួនក៏បានឱ្យបុគ្គលិកនាំគ្នាកាយអាចម៍ដីដាក់ចូលក្នុងបង្គោលវិញ បន្ទាប់មកខ្លួនក៏បានបើករថយន្តមកកន្លែងធ្វើការវិញ។ លុះដល់វេលាម៉ោង១៧ និង២០នាទី ថ្ងៃខែឆ្នាំដដែល ខ្លួនក៏បានបើករថយន្តទៅមើលកន្លែងដាក់ផ្លាកយីហោម្តងទៀត ស្រាប់តែឃើញមានជនជាតិចិន ខ្លួនមិនស្គាល់ឈ្មោះ ជាអ្នកចាំដីឱ្យគេកំពុងកាយអាចម៍ដីបង្គោលស្លាកយីហោលក់ដីឡូតិ៍ ឃើញដូច្នេះ ខ្លួនក៏ហាមជនជាតិចិននោះ ប៉ុន្តែជនជាតិចិននោះមិនបានស្តាប់ឡើយ ។ បន្ទាប់មក ខ្លួនក៏បានបើករថយន្តត្រឡប់មកកន្លែងធ្វើការវិញ ហើយរាយការណ៍ជូនមេតែម្តង ។ លុះព្រឹកឡើងនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង០៧ និង៣០នាទី ខ្លួនបានជិះរថយន្តទៅធ្វើការ ស្រាប់តែបានឃើញ ស្លាកយីហោពុះដីឡូតិ៍បានដួលរលំ ហើយខ្លួនក៏បានតេទូរស័ព្ទរាយការណ៍ជូនមេ រួចខ្លួនក៏បានទៅធ្វើការទៅ។

៣. ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] អៀង នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌÷ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង១២ ថ្ងៃត្រង់ ឈ្មោះ [redacted] ស្រ៊ុ ភេទប្រុស អាយុ៣៩ឆ្នាំ បានតេទូរស័ព្ទចូលមកកាន់ទូរស័ព្ទរបស់ខ្លួន ដោយបានប្រាប់ថាឃើញជនជាតិចិនមិនស្គាល់ឈ្មោះ ដែលជាអ្នកចាំដីនៅជាប់ដីខ្លួន បានមកជីកបង្គោលដាក់ផ្លាកយីហោគម្រោងដីឡូតិ៍ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៥១ ភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល នៅពេលឈ្មោះ [redacted] ស្រ៊ុ ប្រាប់ដូច្នេះ ខ្លួនក៏បានឱ្យឈ្មោះ [redacted] វុទ្ធី ទៅចាំឃ្លាំមើល ។ លុះនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ ឈ្មោះ [redacted] វុទ្ធី បានតេទូរស័ព្ទមកប្រាប់ខ្លួនវិញថា បានឃើញជនជាតិចិនកំពុងជីកបង្គោលផ្លាកយីហោគម្រោងដីឡូតិ៍ឈ្មោះ [redacted] ស្រ៊ុ (MS) ។ បន្ទាប់មកនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង០៧ ព្រឹក ឈ្មោះ [redacted] វុទ្ធី បានតេទូរស័ព្ទមកប្រាប់ខ្លួនថា ផ្លាកយីហោគម្រោងដីឡូតិ៍ឈ្មោះ [redacted] ស្រ៊ុ (MS) ដែលជនជាតិចិនបានជីកនោះ បានដួលរលំហើយ។

៤. ក្របញ្ជីអានពាក្យបណ្តឹង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] វុទ្ធី ។

៥. តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ÷ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមក ឃើញថា កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ ពិតជាមានអំពើធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ហ្វាហុង ប្រាកដមែន។ ឃើញថា មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទខាងលើ។ ហេតុដូចនេះ តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ដូចនៅក្នុងដីកាសន្និដ្ឋានស្ថាពរលេខ១៤៩៤ ដកសព ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៦. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា÷ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមក ឃើញថា កូនក្តីខ្ញុំបាទមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។

ហេតុដូច្នេះ ខ្ញុំបាទសូមរក្សាខ្លឹមសារនៃសេចក្តីសន្និដ្ឋានការពារក្តី ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ទុកជាបានការដដែល និងសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្ញុំរួចខ្លួនពីបទចោទប្រកាន់ ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] HUAHONG ([redacted] ហ្វាហុង)
- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វុទ្ធី
- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺរបស់ឈ្មោះ [redacted] អៀង
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើភស្តុតាងផ្សេងៗនៅក្នុងសំណុំរឿង
- ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១. យល់ឃើញថា នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង០៧ និង០០នាទីព្រឹក ស្ថិតនៅក្នុងភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល មានជនជាប់ចោទឈ្មោះ [redacted] ហ្វាហុង បានធ្វើសកម្មភាពជីកគាស់ផ្លាកយីហោគម្រោងដីឡូត៍ឈ្មោះ MS ខណៈពេលនោះមានឈ្មោះ [redacted] វុទ្ធី ដែលជាមេការលក់ដីឡូត៍ បានចូលទៅហាមឃាត់ជនជាប់ចោទ ប៉ុន្តែជនជាប់ចោទមិនព្រមស្តាប់ឡើយ។ លុះដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង០៧ និង០០ នាទីព្រឹក ឈ្មោះ [redacted] វុទ្ធី ដែលជាមេការលក់ដីឡូត៍ MS បានបើករថយន្តទៅមើលក៏ឃើញផ្លាកយីហោដួលរលំដល់ដីបណ្តាលឱ្យខូចខាត។ ក្រោយមកទើបឈ្មោះ [redacted] វុទ្ធី មកដាក់ពាក្យបណ្តឹងនៅអធិការដ្ឋាននគរបាលស្រុកពញាឮឈានដល់ការឃាត់ខ្លួនជនជាប់ចោទខាងលើតែម្តង។

២. យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] HUAHONG ([redacted] ហ្វាហុង) បានបញ្ជាក់ថា÷ កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង០៧ និង០០នាទីព្រឹក ខ្លួនបានជីកដីបណ្តាលឱ្យប៉ះពាល់ផ្លាក់យីហោគម្រោងដីឡូតិ៍ MS ស្ថិតនៅភូមិផ្សារដែកលើ ឃុំផ្សាដែក ស្រុកពញាឮ ខេត្តកណ្តាល ដោយសារតែផ្លាក់យីហោគម្រោងដីឡូតិ៍ MS នេះធំ បណ្តាលឱ្យប៉ះពាល់កន្លែងស្នាក់នៅរបស់ខ្លួន ហើយកន្លងមក ខ្លួនក៏ធ្លាប់បានប្រាប់ម្ចាស់ផ្លាកយីហោឱ្យលើកចេញដែរ តែមិនយកចេញឡើយ។ ខ្លួនមិនដឹងថាផ្លាកយីហោនោះដួលរលំឬអត់ទេ។

៣. យល់ឃើញថា ផ្អែកតាមអង្គហេតុ, ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ចម្លើយរបស់ជនជាប់ចោទ, ចម្លើយរបស់សាក្សី រួមទាំងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង គឺអាចបញ្ជាក់បានថាដោយសារតែជនជាប់ចោទគិតថាខ្លួនជាម្ចាស់កម្មសិទ្ធិ ហើយផ្លាកលក់ដីឡូតិ៍នៅលើដីរបស់ខ្លួន ទើបជនជាប់ចោទជីកដីផ្តួលផ្លាកយីហោគម្រោងដីឡូតិ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីបណ្តាលឱ្យដួលខូចខាត ។

Scanned with CamScanner

៤. យល់ឃើញថា តាមសំអាងហេតុក្នុងចំណុចទី១ រហូតដល់ចំណុចទី៣ ខាងលើ គឺអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] HUAHONG ([redacted] ហ្វាហុង) ភេទប្រុស ពិតជាបានប្រព្រឹត្តបទល្មើសធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។

៥. យល់ឃើញថា មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] HUAHONG ([redacted] ហ្វាហុង) ភេទប្រុស ជនជាតិចិន ពីបទ÷ ធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ។

៦. យល់ឃើញថា អំពើល្មើស និងសកម្មភាពរបស់ជនជាប់ចោទធ្វើឱ្យខូចសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គលឯកជនដែលច្បាប់បានការពារ និងតម្រូវឱ្យផ្តន្ទាទោស ។

៧. យល់ឃើញថា ពេលធ្វើសកម្មភាព ជនជាប់ចោទខាងលើមានសតិ បញ្ញា ស្មារតី គ្រប់គ្រាន់ប្រព្រឹត្តអំពើល្មើសច្បាប់រហូតសម្រេចតាមបំណងរបស់ខ្លួន ហើយជានីតិជនដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវរាល់អំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

៨. យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វុទ្ធី ភេទប្រុស បានប្តឹងទាមទារសំណងជំងឺចិត្តសរុបចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក ។ ឃើញថា ការប្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មានភាពត្រឹមត្រូវតាមច្បាប់ តប្បិតុលាការធ្វើការពិចារណាអំពីទំហំនៃការខូចខាតជាក់ស្តែង ស្របតាមបញ្ញត្តិមាត្រា១៣ និងមាត្រា១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ សម្រេចសេចក្តី

១. ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] HUAHONG ([redacted] ហ្វាហុង) ភេទប្រុស កើតឆ្នាំ១៩៧១ ជនជាតិចិន ដាក់ពន្ធនាគារ កំណត់រយៈពេល០៦ (ប្រាំមួយ) ខែ ពីបទ÷ ធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ។

២. បង្គាប់ឱ្យឈ្មោះ [redacted] HUAHONG (ហាំង ហ្វាហុង) ភេទប្រុស សងសំណងការខូចខាត និងជម្ងឺចិត្តចំនួន ១,០០០ (មួយពាន់) ដុល្លារអាមេរិក ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វុទ្ធី ភេទប្រុស។ ការទាមទារលើសពីនេះ ត្រូវច្រានចោល ។

សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងកំពាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]



Scanned with CamScanner